# តើយើងអាចរំពឹងអ្វី ពីព្រះជាម្ចាស់ នៅពេលឥឡូវនេះ?

## (សេចក្តីសន្និដ្ឋានបញ្ចប់នៃកម្រងសេចក្តីទាំងនេះ)

ដោយ Tim Geoffrion

## ចូរចងចាំថា៖ ការទុកគឺជាជម្រើសមួយ។



ក្រោយពីការស្ថិតនៅអស់រយៈពេលដ៏យូរ គឺរហូតដល់ ៤០ ឆ្នាំ នៅក្នុងទីរហោស្ថាន លោកយ៉ូស្វេបានដឹកនាំជនជាតិអ៊ីស្រាអែល ឆ្លងកាត់គ្រាច្របូកច្របល់ ក្នុងកាលដែលប្រជាជនខំប្រឹងធ្វើដំណើរទៅតាំងទីលំនៅ នៅក្នុងទឹកដីសន្យា។ មុនពេលលោកម៉ូសេទទួលមរណភាព គាត់បានថ្លែងនៅក្នុងសុន្ទរកថាចុងក្រោយរបស់គាត់ ដោយបានជំរុញ ជនជាតិអ៊ីស្រាអែល ឱ្យយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុត ចំពោះជំនឿ គុណតម្លៃ និងការប្តេជ្ញាចិត្តរបស់ពួកគេ។ នៅពេលពួកគេបានត្រៀមធ្វើដំណើរឆ្ពោះទៅដំណាក់កាលថ្មី នៃជីវិតរបស់ពួកគេ គឺពួកគេចាំបាច់ត្រូវសម្រេចចិត្ត ថាតើពួកគេនឹងទុកចិត្តអ្នកណា ហើយអ្នកណាដែលពួកគេនឹងបំរើ? សុន្ទរកថារបស់លោកម៉ូសេ រួមមានពាក្យល្បីៗ ដល់ពេលបច្ចុប្បន្ន ដែលអាចអនុវត្តបាននៅសព្វថ្ងៃដែរ៖

> ដូច្នេះ ឥឡូវនេះចូរកោតខ្លាចដល់ព្រះយេហូវ៉ា ហើយគោរពប្រតិបត្តិដល់ទ្រង់ដោយចិត្តស្មោះត្រង់ . . . តែបើសិនជាឯងរាល់គ្នាមិនគាប់ចិត្តនឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាទេ នោះចូររើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាម នៅថ្ងៃនេះចុះ . . . តែឯអញ និងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ។
> *យ៉ូស្វេ ២៤:១៤-១៥*

*ពេលដែលខ្ញុំ(សិងតែ)បាត់បង់ជំនឿចំពោះ*

ថ្ងៃមួយ កាលពីពាក់កណ្ដាលទសវត្សឆ្នាំ១៩៩០ ខ្ញុំបានដឹងភ្លាមថា ខ្ញុំមិនទុកចិត្តព្រះ ដូចខ្ញុំធ្លាប់ទុកចិត្តពីមុនទេ។ ខ្ញុំទើបតែមានបទពិសោធន៍រយៈពេល១០ឆ្នាំ នៃការខកចិត្តការខកចិត្ត និងបទពិសោធន៍ឈឺចាប់ក្នុងចិត្ត។ ជំនឿរបស់ខ្ញុំត្រូវរង្គោះរង្គើ។ ខ្ញុំនៅតែថ្វាយបង្គំ និងជឿលើព្រះគ្រីស្ទ ប៉ុន្តែ នៅក្នុងខ្លួនខ្ញុំ មានអ្វីមួយបានផ្លាស់ប្តូរ។ ហើយការផ្លាស់ប្តូរនោះមិនល្អទាំងអស់។

សូមឱ្យខ្ញុំរំឭកផ្នែកខាងដើមនៃរឿងសិន។ ភាពស្រងាកចិត្តជាមួយព្រះជាម្ចាស់ និងព័ន្ធកិច្ច បានចាប់ផ្តើមដក់ជាប់ក្នុងចិត្តខ្ញុំ ប្រហែលមួយឆ្នាំ ក្នុងភាពជាគ្រូគង្វាលដំបូងរបស់ខ្ញុំ។

នៅពាក់កណ្ដាលទសវត្សឆ្នាំ១៩៨០ ប្រពន្ធខ្ញុំ និងខ្ញុំបានបម្រើជាគ្រូគង្វាល នៃក្រុមជំនុំតូចមួយ នៅខាងក្រៅទីក្រុងឈីកាហ្គោ។ ក្នុងអំឡុងពេលបួនឆ្នាំរបស់យើងនៅទីនោះ យើងបានបាត់បង់កូនម្នាក់ ក្នុងការរលូតកូន ហើយមិត្តរួមបន្ទប់របស់ខ្ញុំ មកពីមហាវិទ្យាល័យបានស្លាប់នៅអាយុ ២៨ ឆ្នាំ។ ខ្ញុំបានធ្វើការរហូតដល់ ៧០ ម៉ោងក្នុងមួយសប្តាហ៍ នៅក្នុងព័ន្ធកិច្ច ប៉ុន្តែ ខ្ញុំមិនបានឃើញលទ្ធផល ដែលខ្ញុំបានសង្ឃឹមទុកនោះទេ។ ។ នៅពេលដែលកិច្ចបម្រើដ៏មានអត្ថន័យកំពុងតែកើតឡើង មានរឿងធំៗកំពុងតែធ្វើអោយក្រុមជំនុំនេះ និងព័ន្ធកិច្ចដ៏រស់រវើក ដែលខ្ញុំធ្លាប់មាននិមិត្ត លែងមានការរីកចម្រើន។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាព្រះហាក់ដូចជាមិនបានជួយច្រើនជាងនេះសោះ។

បន្ទាប់មក ខ្ញុំធ្លាក់ខ្លួនឈឺ។ នៅថ្ងៃទី ២៤ ខែមិថុនាឆ្នាំ ១៩៨៦ មួយថ្ងៃបន្ទាប់ពីកូនប្រុសដំបូងរបស់ខ្ញុំកើត ខ្ញុំបានទទួលដំណឹងដ៏គួរឱ្យភ័យខ្លាច។ គ្រូពេទ្យរបស់ខ្ញុំបានទូរស័ព្ទមកខ្ញុំ។ យើងបានធ្វើតេស្តខ្លះ ហើយឥឡូវ គាត់ទទួលបានលទ្ធផល។ គាត់ព្យាយាមពន្យល់វាមកខ្ញុំដោយសុភាព។ ខ្ញុំត្រូវបានគេធ្វើរោគវិនិច្ឆ័យថា មានជំងឺស្បែកធ្ងន់ធ្ងរ។ គាត់បានប្រាប់ខ្ញុំថា ខ្ញុំប្រហែលជានៅសល់ពេលវេលាល្អ ១០ឆ្នាំទៀត។

បានស្ដាប់ការព្យាករណ៍នេះ ដូចជាត្រូវបានគេចាក់នៅក្នុងក្រពះ។ តើមានអ្វីកើតឡើង? ព្រះជាម្ចាស់មិនបានប្រទានពរដល់ការខិតខំរបស់យើងនៅព្រះវិហារ តាមរបៀបដែលខ្ញុំបានរំពឹងទុកនោះទេ។ ទ្រង់មិនបានជួយសង្គ្រោះកូនស្រីរបស់យើង ពីសេចក្តីស្លាប់នោះទេ ហើយឥឡូវនេះ មើលទៅដូចជាកូនប្រុស ដែលទើបនឹងកើតរបស់ខ្ញុំ នឹងលែងមានឪពុកមុនពេលគាត់មានអាយុ ១០ ឆ្នាំ ហើយប្រពន្ធរបស់ខ្ញុំ នឹងក្លាយជាស្ត្រីមេម៉ាយ។

បន្ទាប់មក ម្ដាយខ្ញុំមានជម្ងឺវង្វេងស្មារតី ដែលធ្វើឱ្យគាត់លែងនឹកឃើញអ្វីទាំងស្រុង។ ឪពុកខ្ញុំត្រូវបង្ខំចិត្តចូលនិវត្តន៍មុនពេលកំណត់។ យើងកត់សម្គាល់មើល ដោយអស់សង្ឃឹម នៅពេលសុខភាពរបស់គាត់ បានធ្លាក់ចុះលឿនជាងម្ដាយខ្ញុំទៅទៀត។ មានរឿងតិចតួចណាស់ ដែលយើងអាចជួយពួកគាត់បាន។ សម្រេចសម្រួចទៅ ភាពតានតឹងក្នុងការមើលថែម្ដាយខ្ញុំ បានធ្វើឆក់យកជីវិតឪពុកខ្ញុំ នៅឆ្នាំ១៩៩៨ តាំងពីយូរ មុនពេលដែលម្ដាយខ្ញុំបានស្លាប់នៅឆ្នាំ ២០០២ ទៅទៀត។

អ្វីទាំងអស់នេះមិនសមហេតុផលចំពោះខ្ញុំសោះ។ បើគិតពីអតីតកាល ខ្ញុំដឹងថា ខ្ញុំបានចូលរួមក្នុងព័ន្ធកិច្ចគ្រីស្ទបរិស័ទពេញពេល ដោយមានកិច្ចសន្យាយ៉ាងច្បាស់ជាមួយព្រះ៖ ខ្ញុំគិតថា ប្រសិនបើខ្ញុំបម្រើស្មោះត្រង់ ព្រះអម្ចាស់នឹងថែរក្សាខ្ញុំ។ ឥឡូវនេះ ខ្ញុំមិនដឹងថាតើ "ថែរក្សា" មានន័យដូចម្តេចទេ។ ទោះបីយ៉ាងណាក៏ដោយ អ្វីៗដែលខ្ញុំធ្លាប់រំពឹងនោះ ខ្ញុំដឹងថាខ្ញុំមិនទទួលវាទេ។ ព្រះបានធ្វើឱ្យឪពុកម្តាយខ្ញុំ ក្រុមគ្រួសារខ្ញុំ និងព្រះវិហាររបស់ខ្ញុំ ហើយនិងខ្ញុំផ្ទាល់ ខកចិត្តទាំងអស់ ដូច្នេះ ខ្ញុំបានគិត ហើយការខកចិត្តរបស់ខ្ញុំ បានចាប់ផ្តើមប្រែទៅជាការសង្ស័យ និងភាពជូរចត់។



***ការរកឃើញ ដែលមិននឹកស្មានដល់***

នៅខែមករា ឆ្នាំ ១៩៩៥ ខ្ញុំបានជ្រើសរើសចូលរួមការសម្រាកលំហែខាងវិញ្ញាណរយៈពេល ៨ ថ្ងៃ។ យើងថ្វាយបង្គំព្រះ អធិស្ឋាន ហើយបានធ្វើការពិចារណាស្ថានភាពខាងវិញ្ញាណរបស់យើង។ ខ្ញុំបានស្វែងរកការណែនាំខ្លះពីព្រះ អំពីអនាគតរបស់ខ្ញុំ។ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ចំពោះអ្វីដែលខ្ញុំបានទទួល។

នៅយប់ទីពីរ ខ្ញុំបានដឹងភ្លាមថា ខ្ញុំមិនជឿទុកចិត្តលើព្រះទៀតទេ។ មានការខកចិត្ត និងការឈឺចាប់ខ្លាំងពេក ហើយខ្ញុំបានបន្ទោសព្រះ។ តាមទស្សនៈរបស់ខ្ញុំ គឺព្រះបានអនុញ្ញាតឱ្យខ្ញុំធ្លាក់ចុះ។

ខ្ញុំស្ថិតនៅត្រង់ផ្លូវបំបែក ហើយខ្ញុំបានដឹងខ្លួនច្បាស់។ ខ្ញុំបានដឹងថា ដើម្បីឆ្ពោះទៅមុខទៀត ខ្ញុំនឹងត្រូវធ្វើការសម្រេចចិត្តថាតើខ្ញុំនឹងជ្រើសរើសជឿទុកចិត្តលើព្រះ ឬអត់? ខ្ញុំមិនអាចធ្វើជាអ្នកដឹកនាំគ្រីស្ទបរិស័ទ និងជាគ្រូបង្រៀនបានទេ នៅពេលដែលមានការសង្ស័យ ចំពោះសេចក្តីល្អ និងសកម្មភាពរបស់ព្រះ នៅក្នុងជីវិតរបស់ខ្ញុំ។ **ខ្ញុំបានមើលឃើញបញ្ហា**

**ហើយឥឡូវនេះ ខ្ញុំនឹងត្រូវជ្រើសរើស៖** បន្តឃ្លាតឆ្ងាយពីព្រះ ហើយមានភាពជូរចត់អំពីជំងឺម្តាយខ្ញុំ និងការបាត់បង់ផ្សេងទៀត នៅក្នុងជីវិតរបស់ខ្ញុំ ឬក៏ជ្រើសរើសជឿទុកចិត្តថា ព្រះនៅតែសកម្មក្នុងជីវិតរបស់ខ្ញុំ ដើម្បីអ្វីដែលល្អ ទោះបីខ្ញុំមិនអាចយល់ ឬដឹងច្បាស់ក្តី។

ក្នុងខណៈពេល ដែលមានអារម្មណ៍ដូចជាជញ្ជីងធ្លាក់ពីភ្នែកខ្ញុំ ហើយខ្ញុំអាចមើលឃើញភ្លាមៗ នូវអ្វីដែលខ្ញុំបានធ្វើឱ្យងងឹតភ្នែកខ្លួនឯង។ ខ្ញុំដឹងថាខ្ញុំនឹងមិនអាចបង្ហាញថា ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ និងយកចិត្តទុកដាក់ចំពោះខ្ញុំ ឬថាទ្រង់មិនបានធ្វើនោះទេ។ ផ្ទុយទៅវិញ ខ្ញុំត្រូវធ្វើការជ្រើសរើស។ ខ្ញុំនឹងដើរលើផ្លូវខាងវិញ្ញាណមួយ ឬផ្លូវផ្សេង ( ការមិនជឿ ភាពជូរចត់ ឬការជឿទុកចិត្ត ) ដូច្នេះ តើខ្ញុំនឹងដាក់ជំនឿរបស់ខ្ញុំទៅនរណា ?

នៅពេលដែលរឿងទាំងអស់នេះ ត្រូវបានសម្តែងច្បាស់ចំពោះខ្ញុំហើយ ខ្ញុំដឹងភ្លាមៗថាតើខ្ញុំនឹងជ្រើសរើសយកអ្វី។ ខ្ញុំឈឺដោយសារមានភាពជូរចត់នៅក្នុងចិត្ត  ហើយខ្ញុំចង់ដោះស្រាយការយល់ដឹងដែលខ្ញុំបានជួបប្រទះនោះ។  ជំនួសឱ្យការស្តីបន្ទោសព្រះជាម្ចាស់ ចំពោះបទពិសោធន៍ជីវិតដ៏លំបាករបស់ខ្ញុំ ខ្ញុំអាចទុកចិត្តលើព្រះវរបិតា នៃព្រះយេស៊ូវគ្រីស្ទ និងអ្នកនិពន្ធព្រះគម្ពីរទាំងអស់។ ព្រះអង្គនេះមិនមែនជាមនុស្សចម្លែក សម្រាប់ខ្ញុំទេ ប៉ុន្តែ ជាអ្នកដែលខ្ញុំស្រឡាញ់ ហើយបានស្គាល់ តាមរបៀបមួយប្រកបដោយអត្ថន័យ ជាច្រើនឆ្នាំកន្លងមកនេះ។



*មេរៀនដែលរៀនសូត្របាន*

បទពិសោធន៍ដ៏ឈឺចាប់និងលំបាកនេះ បានបង្រៀនខ្ញុំនូវមេរៀនសំខាន់ៗមួយចំនួន ដែលបានជួយខ្ញុំតាំងពីពេលនោះមក។

- **វាជាការរំពឹងទុករបស់ខ្ញុំអំពីព្រះ ដែលបានធ្វើអោយខ្ញុំខកចិត្ត មិនមែនជាព្រះអ្នកធ្វើឲ្យខ្ញុំខកចិត្តទេ។** និយាយម៉្យាងវិញទៀត គឺការរំពឹងទុកមិនពិតរបស់ខ្ញុំ ដែលថាព្រះនឹងជួយខ្ញុំឱ្យរួចផុតពីការរងទុក្ខ ការឈឺ និងសេចក្តីស្លាប់ បានធ្វើឲ្យខ្ញុំមានការស្រងាកចិត្ត និងចិត្តមិនជឿ។ យោងទៅតាមបទគម្ពីរ ព្រះសន្យាថាការពារ និងថែរក្សាយើងជាទូទៅ ប៉ុន្តែ មិនមែនគ្រប់កាលៈទេសៈទេ។ យើងអាចដឹងគុណចំពោះការផ្គត់ផ្គងនូវគ្រប់ការទាំងអស់របស់ព្រះ នៅក្នុងជីវិត ប៉ុន្តែ យើងមិនគួរគិតថា គ្រីស្ទបរិស័ទនឹងត្រូវបានរួចផុតពីការរងទុក្ខរបស់មនុស្សលោកឡើយ។
- **ការជឿទុកចិត្តគឺជាជម្រើសមួយ** ក្នុងចំណោមកាលៈទេសៈឈឺចាប់ និងភាពមិនច្បាស់នៃជីវិត។ យើងមិនអាចកំណត់ ថាតើព្រះគួរឱ្យទុកចិត្តយ៉ាងតឹងរឹង ដោយផ្អែកលើបទពិសោធន៍របស់យើងទេ។ មានចំណុចទិន្នន័យច្រើនពេក នៅពេលដែលយើងមានអារម្មណ៍ឯកា ការធ្វេសប្រហែស ការបោះបង់ចោល ឬដោយក្តីអាណិតអាសូរពីកម្លាំងផ្សេងទៀត។ ទេ ប្រសិនបើយើងព្យាយាមបន្ថែមហេតុផលទាំងអស់ ដើម្បីជឿទុកចិត្តលើព្រះ តែមួយចំហៀងដែលសមហេតុផល (បូក) ហើយហេតុផលទាំងអស់ដែលមិនគួរទុកចិត្តលើព្រះ នៅម្ខាងទៀត (ដក) យើងនឹងមិនអាចទាញការសន្និដ្ឋានដោយសមហេតុផល ផ្អែកលើបទពិសោធន៍របស់យើងបានទេ។ ផ្ទុយទៅវិញ យើងត្រូវតែសន្និដ្ឋានថា ភ័ស្តុតាងមិនច្បាស់ទេ។ ជម្រើសរបស់យើង គឺត្រូវបោះបង់ចោលជំនឿ ឬ "លោតទៅរកសេចក្តីជំនឿ" ដូចទស្សនវិទូ ដែលគ្រីស្ទបរិស័ទ ឈ្មោះ Soren Kierkegaard ធ្លាប់បានពិភាក្សាដ៏ល្បីល្បាញ។

លោកសាស្ត្រាចារ្យ Henri Nouwen ដែលជាអ្នកនិពន្ធសៀវភៅខាងវិញ្ញាណគ្រីស្ទបរិស័ទលក់ដាច់បំផុត កាលពីនៅរស់ លោកបានសរសេរអំពីជម្រើស ដែលយើងទាំងអស់គ្នាមាន ក្នុងកាលៈទេសៈមិនច្បាស់នៃជីវិត។ គាត់មានប្រសាសន៍ថា,

> នៅកន្លែងដែលមានហេតុផលសម្រាប់ការដឹងគុណ តែងតែអាចរកឃើញមូលហេតុនៃភាពជូរចត់។ គឺនៅទីនេះហើយ ដែលយើងប្រឈមនឹងសេរីភាពក្នុងការសម្រេចចិត្ត។ យើងអាចសម្រេចចិត្តដឹងគុណ ឬជូរចត់។
> *ជីវិតនៃអ្នកជាទីស្រឡាញ់។ ការរស់នៅខាងវិញ្ញាណ ក្នុងពិភពលោកខាងលោកីយ៍ ទំព័រ ៦១*

នៅពេលដែលយើងក្រឡេកមើលទុក្ខវេទនា ការខាតបង់របស់យើង រាល់អ្វីដែលខុសនឹងលោកីយ និងបញ្ហា ព្រមទាំងការលំបាកទាំងអស់ ដែលយើងត្រូវប្រឈមមុខ យើងអាចមានអារម្មណ៍ថា គ្មានអំណាចនៅគ្រានោះទេ តែយើងមិនអញ្ចឹងទេ។ យើងមានអំណាច ដើម្បីជ្រើសរើសអាកប្បកិរិយារបស់យើង។ យើងអាចសម្រេចចិត្តថា នៅជាប់នឹងព្រះ ដែលយើងស្គាល់ និងស្រលាញ់ ទោះបីជាមានសំណួរនិងចម្លើយ ដែលពិបាកឆ្លើយជាច្រើនក៏ដោយ។ យើងអាចមើលកាលៈទេសៈរបស់យើង តាមរយៈក្រសែភ្នែកនៃសេចក្តីជំនឿ។ យើងអាចជ្រើសរើសការដឹងគុណ ចំពោះរបៀបដែល

យើងមើលឃើញព្រះ នៅកន្លែងធ្វើការ នៅក្នុងជីវិតរបស់យើង ហើយទុកអ្វីៗដែលនៅសល់កន្លងផុតទៅដោយខ្លួនវាចុះ។



*មេរៀនសម្រាប់ការអនុវត្តខាងវិញ្ញាណ*

ចម្លើយចំពោះការសង្ស័យ និងការស្រងាកចិត្តចំពោះព្រះ គឺមិនមែនធ្វើព្រងើយកន្តើយចំពោះការសង្ស័យរបស់អ្នកឡើយ។ មិនមែនធ្វើពុតដូចជាអ្នកមិនមានសំណួរ ឬការឈឺចាប់ក្នុងចិត្តទេ។ ក៏មិនមែនព្យាយាមបង្ខំខ្លួនអ្នក និងអ្នកដទៃឱ្យជឿ ដោយគ្រាន់តែអធិប្បាយកាន់តែលឺជាងមុន និងពេញដោយកម្លាំងនោះទេ។

ទេ ចម្លើយចំពោះការសង្ស័យ ចាប់ផ្តើមដោយការទទួលស្គាល់ថា មានរឿងជាច្រើន ដែលអ្នកមិនយល់អំពីព្រះ អំពីខ្លួនអ្នក និងអំពីជីវិតនេះ ហើយក៏ប្រហែលជានឹងមិនអាចយល់រហូតក៏ថាបាន។ ប៉ុន្តែ មិនថាវាងងឹតដល់ថ្នាក់ណាក្តី ទោះបីជាអ្នកអាចមានអារម្មណ៍បង្វេង ឬឈឺចាប់ប៉ុណ្ណាក៏ដោយ នៅពេលអ្នកឈានដល់ទីបញ្ចប់នៃសមត្ថភាពរបស់អ្នកក្នុងការវែកញែកញែកតាមវិធីរបស់អ្នក ហើយដាក់ថ្វាយទៅព្រះវិញ នោះអ្នកនៅតែអាចសម្រេចចិត្តទុកចិត្តលើព្រះដែលបានបង្កើតអ្នកមក ហើយនិងព្រះយេស៊ូវគ្រីស្ទដែរ។ អ្នកនៅតែអាចឈានទៅមុខ ក្នុងសេចក្តីជំនឿ។

ហើយ កាលណាអ្នកធ្វើដូច្នោះ៖

- អ្នកនឹងទទួលបាននូវសេចក្តីសុខ ហួសការដែលអ្នកអាចយល់ដឹង។
- អ្នកនឹងមានសេរីភាពក្នុងការប្រើប្រាស់ថាមពលរបស់អ្នក ក្នុងគោលបំណងនៃការជួយស្អាងចិត្តឡើង។
- អ្នកនឹងមានចរឹតសុភាពរាបសា និងសប្បុរសចំពោះអ្នកដទៃ ហើយមានមនោសញ្ចេតនាកាន់តែច្រើន ដើម្បីជួយព្រមទាំងគាំទ្រពួកគេ។

- អ្នកនឹងអាចស្តាប់បានល្អជាងមុន ចំពោះអ្វីដែលព្រះចង់មានបន្ទូលទៅកាន់អ្នក នៅចំពេលដែលមានភាពមិនប្រាកដប្រជា និងការរងទុក្ខរបស់អ្នក។
- អ្នកនឹងមានបទពិសោធន៍សេចក្តីអំណរក្នុងជីវិត ដែលពេញដោយព្រះវិញ្ញាណ និងដឹកនាំដោយព្រះវិញ្ញាណ។

សូមឲ្យព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង និងព្រះដ៏ជាព្រះវរបិតា ដែលទ្រង់បានស្រឡាញ់យើង ព្រមទាំងប្រទានឲ្យមានសេចក្តីកំសាន្តអស់កល្បជានិច្ច និងសេចក្តីសង្ឃឹមយ៉ាងល្អ ដោយព្រះគុណទ្រង់ ។ បានកំសាន្តចិត្តអ្នករាល់គ្នាដែរ ហើយតាំងឲ្យអ្នករាល់គ្នាបានមាំមួនឡើង ក្នុងគ្រប់ទាំងការ និងពាក្យសំដីដ៏ល្អផង។
*២ថែស្សាឡូនីច ២:១៦-១៧*

---

*នឹងមកដល់ឆាប់ៗនេះ៖ អត្ថបទថ្មីៗស្តីពីជំហានបន្ទាប់ សម្រាប់ការធ្វើដំណើរឆ្លងកាត់វិបត្តិសេដ្ឋកិច្ច ដែលកំពុងបន្ត ក្នុងនាមជាអ្នកដើរតាមព្រះគ្រីស្ទ ដែលដឹកនាំដោយព្រះវិញ្ញាណ។*

---

Copyright © 2020 Timothy C. Geoffrion, Wayzata, Minnesota. All rights reserved to the author, but readers may freely download, print, forward, or distribute to others, providing that this copyright notice is included.
រក្សាសិទ្ធ © 2020 Timothy C. Geoffrion, ទីក្រុង Wayzata, រដ្ឋមីនេសូតា។ ក្សាសិទ្ធិគ្រប់បែបយ៉ាងជូនចំពោះអ្នកនិពន្ធ ប៉ុន្តែ ប្រិយមិត្តអាចទាញយក បោះពុម្ព បញ្ជូន ឬចែកចាយបន្តដល់អ្នកដទៃទៀតដោយសេរី គ្រាន់តែសូមរក្សាចំណារសម្គាល់នៃការរក្សាសិទ្ធិនេះជាមួយផង។
ប្រែសម្រួលភាសាដោយ: លី ប៊ុនថា

---

ដើម្បីអានអត្ថបទតែងសេចក្តីមុនៗ ជាភាសាភូមា ឬភាសាកុលសម្ព័ន្ធឈីន សូមចូលទៅ { HYPERLINK "https://fhlglobal.org/" } ។

---

**បរិបទ៖ ខ្ញុំបានបង្កើតកម្រងសំណេរតែងនេះដើម្បីឆ្លើយតបទៅនឹងវិបត្តិជាសកល នៃជំងឺកូវីដ -២៩ តាមរយៈការបង្រៀនតាមព្រះគម្ពីរ គឺសមហេតុផលនៅក្នុងស្ថានភាពដែលមានការរងទុក្ខលំបាកជាច្រើន របស់មនុស្សជាតិ។ តែងសេចក្តីនីមួយៗ មានបន្ថែម ជូននូវការអនុវត្តជាក់ស្តែង ដែលត្រូវបានផ្តល់ជូន នៅក្នុងសៀវភៅមានចំណងជើងថា អ្នកដឹកនាំដែលមានព្រះវិញ្ញាណទ្រង់នាំ៖ ប្រាំបួនគោលការណ៍នៃភាពជាអ្នកដឹកនាំ និងគោលការណ៍ខាងព្រលឹងវិញ្ញាណ ( HERNDON, VA: ALBAN INSTITUTE, ឆ្នាំ ២០០៥ ) ទំព័រ ១៨៤-៩០ ។**

---

Photo Credits:
- Photo of man at crossroads courtesy of Vladislav Babienko

- Photos by Timothy Charles Geoffrion (**{** HYPERLINK "http://www.thiswalkinglife.com/" **}**): highway in Wyoming desert; sunrise at Grand Staircase, Escalante National Monument, Utah; and Crown Jewel of the Continent, in Glacier National Park, Montana. Thank you!

---

**សូមជួយយើងខ្ញុំផ្សព្វផ្សាយពាក្យលើកទឹកចិត្តល្អៗ**! សូមជួយចែករំលែកអត្ថបទតែងសេចក្តីទាំងនេះ ជាមួយមនុស្សឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ប្រសិនបើអ្នកមានការប៉ះពាល់ចិត្ត ឬទទួលបានការលើកទឹកចិត្ត ដោយសារអត្ថបទមួយ ឬច្រើន សូមជួយផ្សព្វផ្សាយ ដោយចែករំលែកពាក្យលើកទឹកចិត្តនេះ **ដោយការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់យើងខ្ញុំ ក្នុងការបកប្រែជាភាសាផ្សេងៗ ហើយចែករំលែកទៅទូទាំងពិភពលោកទាំងមូល តាមរយៈ<u>ការបរិច្ចាគទៅព័ន្ធកិច្ចសកល សម្រាប់សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ នៅថ្ងៃនេះ</u>។**